**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**អគ្គនាយកដ្ឋានកសិកម្ម**

លេខ ៩៧៤ អ.ន.ក

ថ្ងៃអង្គារ ២កើត ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៩

**សូមគោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ៖** របាយការណ៍ស្តីពីសកម្មភាពអនុវត្តការងារប្រចាំខែមេសា ឆ្នាំ២០១៩ របស់អគ្គនាយកដ្ឋានកសិកម្ម។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមអនុញ្ញាតរាយការណ៍ជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបនូវលទ្ធផលអនុវត្តសកម្មភាពការងាររបស់អគ្គនាយកដ្ឋានកសិកម្មប្រចាំខែមេសា ឆ្នាំ២០១៩ មានដូចខាងក្រោម៖

## I. លទ្ធផលអនុវត្តការងារតាមនាយកដ្ឋាន

## ១. នាយកដ្ឋានរដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការអន្តរជាតិ

### ១.១ ការងារកិច្ចការរដ្ឋបាល

ក្នុងខែមេសា ឆ្នាំ២០១៩នេះ អគ្គនាយកដ្ឋានកសិកម្មបានទទួលលិខិតចូលចំនួន ៩៨៨ច្បាប់ បានបញ្ជូនលិខិតចេញចំនួន ៧០០ច្បាប់ និងបានចេញលិខិតបញ្ជាបេសកកម្មចំនួន ៦៧១ច្បាប់។

### ១.២ ការងារបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស

មកដល់ពេលនេះ អគ្គនាយកដ្ឋានកសិកម្មមានមន្ត្រីរាជការបម្រើការងារសរុបចំនួន ៥៧៨នាក់ (ស្ត្រី១៦៨នាក់) ស្មើនឹង២៨,៦៧% និងតាមក្របខ័ណ្ឌ"ក" មានចំនួន ៣៥៦នាក់ (ស្ត្រី៩២នាក់) ក្របខ័ណ្ឌ"ខ" មានចំនួន ១៣១នាក់ (ស្ត្រី៤៣នាក់) និងក្របខ័ណ្ឌ"គ" មានចំនួន ៩០នាក់ (ស្ត្រី៣៣នាក់)។ មន្ត្រីស្ថិតនៅក្រៅក្របខណ្ឌដើមមានចំនួន ០១នាក់ និងមន្ត្រីដែលបានចេញទៅវគ្គបណ្តុះបណ្តាលក្រៅប្រទេសចំនួន ០២នាក់។

### ១.៣ ការងារផែនការ និងស្ថិតិ

- ធ្វើរបាយការណ៍បច្ចុប្បន្នភាពប្រចាំថ្ងៃ និងចុះពិនិត្យការងារបង្កបង្កើនផលកសិកម្មតាមខេត្តគោលដៅ
- បូកសរុបរបាយការណ៍ប្រចាំខែរបស់អគ្គនាយកដ្ឋានកសិកម្ម
- ចុះពិនិត្យ និងតាមដានអនុវត្តថវិកាកម្មវិធីរបស់អង្គភាពជំនាញក្រោមឱវាទអគ្គនាយកដ្ឋានកសិកម្ម
- បានប្រជុំរៀបចំផែនការយុទ្ធសាស្ត្រថវិកា៣ឆ្នាំរំកិល២០២០-២០២២ របស់អគ្គនាយកដ្ឋានកសិកម្ម
- រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍អនុវិស័យដំណាំឆ្នាំ២០១៩-២០២៣ របស់អគ្គនាយកដ្ឋានកសិកម្ម។

### ១.៤ ការងារគណនេយ្យ និងហិរញ្ញវត្ថុ

- ធ្វើបុរេប្រទានប្រចាំខែមេសាឆ្នាំ២០១៩ជុំទី១ និងរៀបចំបញ្ជីបេឡាប្រចាំថ្ងៃ ប្រចាំខែ
- ផ្ទៀងផ្ទាត់សំណើសុំដក និងចំណាយថវិការជូទេយ្យបុរេប្រទានជុំទី១ ឆ្នាំ២០១៩
- ធ្វើបេសកកម្ម រៀបចំទូទាត់ និងរៀបចំប័ណ្ណចំណូល ចំណាយ
- បើកសម្ភារៈសម្រាប់អនុវត្តសកម្មភាពឆ្នាំ២០១៩ និងបញ្ចូលទ្រព្យសម្បត្តិរដ្ឋចូលក្នុងប្រព័ន្ធកុំព្យូទ័រ
- គ្រប់គ្រងសេវាសាធារណៈ និងទទួលចំណូលពីសេវាសាធារណៈ។